**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :......០០៣/២៦...............**ក.ប/ខ.ល**

# សារលិខិតជូនពរ

**សូមគោរពជូន**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**
**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត អគ្គស្នងការ នៃសមាគមកាយឫទ្ធិនារីកម្ពុជា**

***ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

ក្នុងឱកាសដ៏សិរីមង្គលនៃខួបអាពាហ៍ពិពាហ៍ គម្រប់ ២០ឆ្នាំ របស់ **សម្តេចមហាបវរធិបតី** និង **លោកជំទាវបណ្ឌិត** ខ្ញុំបាទ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមគោរពអនុញ្ញាតចូលរួមអបអរសាទរនូវចំណងអាពាហ៍ពិពាហ៍ដ៏គំរូប្រពៃ ជាគូបុព្វេសន្និវាស ដែលពោរពេញដោយភាពផ្អែមល្ហែម និងភាពស្មោះស្ម័គ្រចំពោះគ្នាជាអមតៈ។ ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំ សូមអនុញ្ញាតសម្តែងនូវការគោរពដឹងគុណជាអនេកប្បការចំពោះលោកទាំងទ្វេ ដែលបានប្រកៀកស្មាគ្នាយ៉ាងម៉ឺងម៉ាត់ ដោយ **សម្តេចធិបតី** បាននិងកំពុងដឹកនាំប្រទេសឱ្យទទួលបាននូវសន្តិភាព និងសុខសុវត្ថិភាពជូនប្រជាជន កងកម្លាំងប្រដាប់អាវុធ និងវីរកងទ័ពជួរមុខនៃយើង តាមរយៈការជ្រើសយកយន្តការការទូតដើម្បីដោះស្រាយជម្លោះព្រំដែនដោយសន្តិវិធី ព្រមទាំងបានរួមដំណើរជាមួយ **លោកជំទាវបណ្ឌិត** ក្នុងនាមជាស្ត្រីទី១នៃកម្ពុជា ចុះសួរសុខទុក្ខកងកម្លាំងប្រដាប់អាវុធ និងបងប្អូនវីរកងទ័ពដែលសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យ បានលើកទឹកចិត្ត បំផុសស្មារតីស្នេហាជាតិ សាមគ្គីជាតិ និងសូមឱ្យប្រជាពលរដ្ឋរក្សានូវសេចក្តីថ្លៃថ្នូរក្នុងនាមជាជាតិខ្មែរ។ បន្ថែមពីនេះ **លោកជំទាវបណ្ឌិត** បានចុះជួបសំណេះសំណាល និងឧបត្ថម្ភគាំទ្រដល់ប្រជាពលរដ្ឋភៀសសឹក និងក្រុមគ្រួសារវីរកងទ័ពដល់ទីតាំងជំរំភៀសសឹកផ្ទាល់ផងដែរ។ ពិតប្រាកដណាស់ថា សកម្មភាពទាំងនេះបានធ្វើឱ្យប្រជាពលរដ្ឋខ្មែរគ្រប់រូបជាសមរភូមិក្រោយ ទទួលបាននូវសុខភាពផ្លូវចិត្តរឹងមាំ និងមានឆន្ទៈរួបរួមគ្នាជាធ្លុង ក្នុងការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងដល់បងប្អូនប្រជាពលរដ្ឋភៀសសឹក ក្រុមគ្រួសារវីរកងទ័ព និងជាកម្លាំងចិត្តដល់កងកម្លាំងប្រដាប់អាវុធ និងវីរកងទ័ពសមរភូមិមុខ អាចការពារជាតិ មាតុភូមិ បានយ៉ាងរឹងមាំ និងប្រកបដោយស្មារតីមោទនភាពជាតិ។

នាឱកាសដ៏ឧត្តុង្គឧត្តមនេះ យើងខ្ញុំ សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាក្នុងព្រះរាជាណាចក្រកម្ពុជា សូមប្រោះព្រំសព្ទសាធុការពរ សិរីសួស្តី ជ័យមង្គល វិបុលសុខបវរមហាប្រសើរ ជូនចំពោះ **សម្តេចមហាបវរធិបតី** និង**លោកជំទាវបណ្ឌិត** ព្រមទាំងក្រុមគ្រួសារជាទីស្រឡាញ់ សូមសមប្រកបដោយព្រះពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត អគ្គស្នងការ នៃសមាគមកាយឫទ្ធិនារីកម្ពុជា** មេត្តាទទួលនូវគារវកិច្ចភាពដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

ថ្ងៃសុក្រ ១៤កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មករា ឆ្នាំ២០២៦

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**ហេង សួរ**